AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ

# ច្បាប់ក្រមង៉ុយ

~ ច្បាប់ល្បើកថ្មី

~ ច្បាប់កេរកាលថ្មី

~ សេចក្តីរំលឹកដាស់តឿន

~ ពាក្យកាព្យប្រដៅជនប្រុសស្រី



ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥១៦

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

# ច្បាប់ក្រមង៉ុយ

- ច្បាប់ល្បើកថ្មី
- ច្បាប់កេរកាលថ្មី
- សេចក្តីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



## **អារម្ភកថា**

ច្បាប់ក្រមង៉ុយនេះកាលបោះពុម្ពលើកមុនៗ ចែកចេញជាបីសៀវភៅ គឺសៀវភៅទី១ មានច្បាប់ល្បើកថ្មី និងកេរកាលថ្មី. ទី២ សេចក្តីដាស់តឿន និងទី៣ពាក្យកាព្យប្រដៅជនប្រុសស្រី ។ នៅគ្រាបោះពុម្ពលើកទី៦នេះ ដោយនិយមតាមសេចក្តីស្នើពីមជ្ឈដ្ឋានអ្នកសិក្សាជាច្រើននាក់ដែលសុំអោយយើងផ្តុំគ្នាយកច្បាប់នេះមករួមគ្នាជាសៀវភៅមួយ ត្បិតទុកអោយនៅដោយឡែកៗជាកូនសៀវភៅតូចៗនោះនាំអោយរប៉ាត់រប៉ាយ ពិបាកថែរទាំ ។ យោបល់នេះត្រឹមត្រូវណាស់ ទើបយើងសម្រេចប្រមូលផ្តុំបានជាសៀវភៅមួយនេះឡើង ។

ចំពោះពាក្យពេចន៍ កាព្យឃ្លោងទាំងអស់នៅក្នុងច្បាប់ទាំងប៉ុន្មាននេះ យើងគ្មានប៉ះពាល់កែប្រែសោះឡើយ សម្រួលតែរបៀបតម្រៀបឃ្លាល្បះអោយមានលំនាំទៅតាមបែបកាព្យត្រឹមត្រូវប៉ុណ្ណោះ ។

គោលបំណងធំរបស់យើងខ្ញុំមួយទៀត គឺការចង់រក្សាស្នាដៃដ៏មានតម្លៃនៃលោកតាកវី **ភិរម្យង៉ុយ ឬក្រមង៉ុយ** ព្រោះពាក្យសំដីរបស់លោកក្នុងនេះទាំងអស់សុទ្ធតែមានន័យទូលំទូលាយ ហើយប្រកបដោយខ្លឹមសារល្អណាស់មិនចេះហួសសម័យកាលនោះផង តាំងពីគ្រាលោកសរសេររហូតសព្វថ្ងៃនៅតែមានន័យត្រូវគួរនិងធ្វើគតិទូន្មានខ្លួនបាន ។

ឆ្លៀតឱកាសនេះ ពុទ្ធសាសនបណ្ឌិតសុំសម្តែងគារវកិច្ចដ៏ជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធនៃលោកកវីដ៏ឆ្នើមនេះផង ។

ភ្នំពេញ ខែ សីហា ឆ្នាំ ១៩៧២

**ពុទ្ធសាសនបណ្ឌិត្យ**

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

# ជីវប្រវត្តិ
# អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ
( 1865 - 1936 )

អ្នកព្រះភិរម្យភាសាអ៊ូ, ឈ្មោះពេញ អ៊ុក អ៊ូ ហៅ ង៉ុយ កើត នៅ គ.ស ១៨៦៥ ( ព.ស ២៤០៨ ) នៅភូមិព្រៃអណ្តូងស្វាយ ឃុំកំបូល ស្រុកភ្នំពេញ, ខេត្តកណ្តាល ។

- បិតាលោកនាម អ៊ុក ធ្វើមេឃុំកំបូល មានគោរម្យងារ ជា «ចៅពញាធម្មធារា» ។ ចៅពញាអ៊ុក ជាប់ជាសាច់ញាតិនឹងម្ចាស់អង្គប៉ុក ។

- មាតាលោកនាម អៀង ជាបុត្រីរបស់ចៅពញា ម៉ុក មេឃុំ ស្ពានថ្ម ស្រុកខេត្តជាមួយគ្នា ។ មាតានិងបិតាលោក ត្រូវជាបងប្អូនជីទួត មួយនឹងគ្នា ។ លោកជាកូនទីពីរ នៅក្នុងគ្រួសារ ។

កាលពីនៅវ័យកុមារ លោកបានរៀនសូត្រលេខនព្វន្ត អក្សរៈ សាស្ត្រ នៅវត្តអង្គបឹងចក ភូមិបែកស្គរ ឃុំបែកចាន ក្នុងស្រុកកំណើត របស់លោក ។ កុមារ អ៊ុក អ៊ូ ជាក្មេងម្នាក់ឧស្សាហ៍រៀនសូត្រ ។ លោក បានបួសជាសាមណេរនៅក្នុងវត្តនោះ ។ ប៉ុន្មានឆ្នាំក្រោយមក លោកបាន លាចាកសិក្ខាបទទៅបំរើមាតាបិតា ហើយបានធ្វើជាស្មៀន របស់ឪពុក លោកក្នុងការដើរហូតពន្ធស្រូវអាជ្ញាហ្លួង ។ លុះអាយុបាន ២១ ឆ្នាំ លោក បានបំពេញឧបសម្បទាជាភិក្ខុ នៅក្នុងវត្តដដែល ដោយមានព្រះឧបជ្ឈាយ៍ នាម *សាស់* និងលោកគ្រូសូត្រស្តាំនាម *ជ្រូក* ជាកម្មវាចា, លោកគ្រូសូត្រ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ឆ្វេងនាម *អ៊ុំង* ជាអនុស្សាវរៈ ។ ភិក្ខុ អ៊ុំ បានរៀនសូត្រធម៌អាចិ និងរៀនប្រែព្រះត្រៃបិដកដំបូង ក្នុងសំណាក់លោកគ្រូអាចារ្យ « ទិត្យ » នៅវត្តអង្គបឹងចក ។ បន្ទាប់មក លោកបានស្វែងរករៀនវិបស្សនាកម្មដ្ឋាន ក្នុងសំណាក់លោកអាចារ្យជាច្រើនកន្លែងទៀត ។ លោកបានគង់ក្នុងផ្នួសជាភិក្ខុបាន ៥ ឆ្នាំ ។ លុះចេះដឹងល្មមប្រើការបានហើយ លោកបានលាចាកសិក្ខាបទ មកប្រកបជីវភាពជាគ្រហស្ថវិញ ។ ក្រោយពេលលោកចាកផ្នួសមក លោកបានជួយធ្វើការឪពុករបស់លោកដែលជាមេឃុំ ដោយមានងារជាក្រមផង ជាស្មៀនផង ។ ដល់ពេលស្រុកភ័ន្តប្រែ លោកលាឈប់លែងធ្វើការរាជការ ហើយរស់នៅជាកសិករធម្មតា ។

លោកជាអ្នកមានវោហារលែបខាយ ប្រាជ្ញាវាងវៃ ចេះចាំរឿងរ៉ាវពីបុរាណៗ ទាំងគតិលោក ទាំងគតិធម៌ជាច្រើន ព្រមទាំងចេះច្រៀង ចេះភ្លេង និងជាអ្នកចម្រៀងខ្សែដៀវយ៉ាងចំណាន ធ្វើឱ្យកសិករឯទៀតស្រឡាញ់រាប់អាន ទុកលោកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយគេនិយមហៅលោកថា « ភិរម្យង៉ុយ » ។ លោកភិរម្យង៉ុយ មានមាឌធំ ដុះក្បាលពោះ កាត់សក់ជ្រងខ្លី ទុកពុកមាត់ខាងលើ និយមស្លៀកសំពត់ចងក្បិន ពាក់អាវកត្រង់ ឡេវធំ ពាក់ស្បែកជើងផ្ទាត់ និងមួកសំបុក ។ ពេលដើរទៅណាមកណា លោកមានបង្វិច និងឈើច្រត់កាន់ជានិច្ច ។ ពេលលោកសូត្រកំណាព្យ លោកតែងដេញខ្សែដៀវកំដរ ។ ខ្សែដៀវរបស់គាត់ អាចដោះចេញពីគ្នា ហើយតម្លើងបានភ្លាមៗ កាលណាគាត់ត្រូវការប្រើ ។ ពេលណាលោកត្រូវការច្រៀង លោកស្រាយបង្វិចយកឃ្លោកសាដៀវមកផ្គុំនឹងឈើច្រត់ បានជាដងជាផ្លែ ហើយដាក់ខ្សែ រួចផ្ចាប់នឹងពោះធ្វើធីតប៉ោងៗ ហើយ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ដេញយ៉ាងពិរោះ ។

ពេលរដូវរំហើយ ក្រោយពីការងារស្រែចំការបានចប់សព្វគ្រប់ លោកតែងត្រូវបានប្រជាជនអញ្ជើញឱ្យទៅច្រៀង ឬទេសនា ក្នុងពេលមានបុណ្យទាន ពីភូមិមួយទៅភូមិមួយ ។ លោកមិនបានទារប្រាក់កំរៃឈ្នួលពីប្រជាជនទេ ប៉ុន្តែ ដោយសេចក្តីគោរពស្រឡាញ់ ប្រជាជនតែងប្រមូលបច្ច័យ ស្រូវអង្ករជូនលោកតាមសទ្ធា ។ ពេលធ្វើដំណើរឆ្លងកាត់ក្រុងភ្នំពេញ លោកតែងឈប់សំចតនៅវត្តឧណ្ណាលោម ហើយឆ្លៀតពេលនោះដើម្បីពិគ្រោះពិភាក្សាជាមួយសាមណេរ-ភិក្ខុសង្ឃ អំពីបញ្ហាផ្សេងៗដែលទាក់ទងនឹងព្រះពុទ្ធសាសនា ។

ក្នុងការច្រៀងក្តី ទេសនាក្តី លោកតែងលើកយកបញ្ហាដែលជាបច្ចុប្បន្នភាពក្នុងពេលនោះ មកធ្វើជាប្រធានបទ ដូចជាច្រៀង ៖

- អំពីការប្រកបមុខរបររកស៊ីធ្វើស្រែចំការ,
- អំពីការជ្រើសរើសគូស្រករ,
- អំពីភាពក្រីក្រគោកយ៉ាករបស់ប្រជាជន និងមូលហេតុរបស់វា,
- អំពីអវិជ្ជា អនក្ខរភាព របស់ប្រជាជនខ្មែរ,
- អំពីភាពស្ពឹកស្រពន់ មិនសកម្ម ស្ងាហាប់ខាងធ្វើពលកម្មដាំដុះ,
- អំពីការបែកបាក់សាមគ្គី ឈ្លោះទាស់ទែងតែគ្នាឯង ទាំងគ្រហស្ថ ទាំងអ្នកបួស,
- អំពីការជិះជាន់សង្កត់សង្កិនរបស់បរទេស មកលើប្រជាជនខ្មែរ
- អំពីការបាត់បង់ឯករាជ្យ និង អត្តភាពខ្មែរ,

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com


- អំពីការវេចរឹលនៃវប្បធម៌ អក្សរសាស្ត្រខ្មែរ ។ ល ។

កិត្តិស័ព្ទល្បីល្បាញខាងសំនួនវោហាររបស់កវី អ៊ូ នេះ បានឮខ្ចរខ្ចាយទៅដល់ព្រះមហាក្សត្រ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងព្រះស៊ីសុវត្ថិ បានត្រាស់ហៅលោកឱ្យចូលគាល់ និងច្រៀងថ្វាយ ។ ហ្លួងព្រះស៊ីសុវត្ថិ ពេញព្រះទ័យនឹងថ្វីមាត់របស់លោកណាស់ ទើបអនុញ្ញាតឱ្យលោកចូលបំរើក្នុងក្រុមភ្លេងព្រះបរមរាជវាំង ហើយប្រទានងារជា « អ្នកព្រះភិរម្យភាសាអ៊ូ » ប៉ុន្តែ ដោយនៅពេលនោះ មាននាយក្រុមវាំងម្នាក់ឈ្មោះអ៊ូ ដែរនោះ ទើបហ្លួងព្រះស៊ីសុវត្ថិ ទ្រង់ត្រាស់ឱ្យហៅថា « ង៉ុយ » វិញ ដើម្បីកុំឱ្យច្រឡំគ្នា ។ ដូច្នេះបានជាលោកមានឈ្មោះ ១ ទៀតថា « ង៉ុយ » ឬ ក្រមង៉ុយ រៀងដរាបមក ។

កិត្តិស័ព្ទរបស់អ្នកព្រះភិរម្យភាសាអ៊ូ មិនគ្រាន់តែល្បីរន្ទឺនៅក្នុងប្រទេសទេ ប៉ុន្តែ បានសាយភាយទៅដល់ប្រទេសថៃ ថែមទៀត ។ ស្តេចសៀម ក្រុមព្រះទំរង់រាជានុភាព និងលោកសីដេស ជាតិបារាំង បានចូលគាល់ហ្លួងព្រះស៊ីសុវត្ថិ ។ ពេលប្រគំភ្លេងទទួលភ្ញៀវបរទេសនោះ អ្នកព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ ប្រគំឈ្មោះគេខាងខ្សែដៀវ ។ កិត្តិស័ព្ទរបស់លោកបានផ្សាយដល់ស្រុកសៀម ។ ស្តេចសៀមបានធ្វើរាជសារមកសុំអញ្ជើញអ្នកព្រះភិរម្យភាសាង៉ុយ ទៅច្រៀងថ្វាយ ឯក្រុងបាងកក ។ លោកបានធ្វើដំណើរទៅនៅស្រុកសៀម អស់រយៈពេល ៣ ខែ ហើយបានទទួលសេចក្តីរាប់អានពីសំណាក់ព្រះមហាក្សត្រ និងមន្ត្រីសៀម ។ ពេលនោះស្តេចសៀមបានប្រទានងារជាភិរម្យភាសា « ផៃរ៉ោះសៀក៏ន » និងប្រទាន

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ឡេវអាវប្រាក់ខ្លង ព្រមទាំងប្រាក់ និងវត្ថុផ្សេងៗទៀតជាច្រើន ។ មានដំណាលថា ក្នុងពេលធ្វើដំណើរត្រឡប់ពីប្រទេសសៀមវិញ លោកបានឆ្លងកាត់តាមខេត្តបាត់ដំបង ។ ពេលនោះ នៅខេត្តបាត់ដំបង មានអ្នកចម្រៀងមាត់ឯកម្នាក់ ឈ្មោះភិរម្យយូ ។ ដោយឮល្បីថា អ្នកព្រះភិរម្យភាសាអ៊ូ ពូកែច្រៀង លោកភិរម្យយូ ក៏មកសុំច្រៀងភ្នាល់ ។ ភិរម្យយូបានសួរព្រះភិរម្យង៉ុយថា « *ភ្នំព្រះសុមេរុនៅឯណា ? មានទំហំប៉ុណ្ណា ? កំពស់ប៉ុន្មានយោជន៍ ? ពីនេះទៅ បើសិនជាវាស់ តើមានប៉ុន្មានគីឡូម៉ែត្រ ?* » ។ ព្រះភិរម្យង៉ុយឆ្លើយថា « *បើលោកឆ្ងល់យ៉ាងនេះ តើលោកចង់ឱ្យខ្ញុំឆ្លើយត្រង់ ឬឱ្យឆ្លើយកុហក ?* » ។ ភិរម្យយូថាបើសួរ*ត្រង់ ត្រូវតែឆ្លើយឱ្យត្រង់* ។ ភិរម្យង៉ុយ ក៏ឆ្លើយកែដោះសារថា មានប៉ុណ្ណេះគីឡូ ប៉ុណ្ណេះម៉ែត្រ ហើយបើគិតពីបាត់ដំបងទៅ មានចម្ងាយផ្លូវប៉ុណ្ណេះទៀត បើភិរម្យយូ មិនជឿត្រូវទៅមើលចុះ ។ ភិរម្យយូ ព្រមទទួលជឿ ហើយភិរម្យង៉ុយ ក៏សួរវិញថា « *តើពីផ្សារបាត់ដំបង ទៅភ្នំពេញ បើទៅតាមថ្នល់ តើមានប៉ុន្មានគីឡូ ? បើទៅតាមទន្លេសាបវិញ តើមានប៉ុន្មានគីឡូ ?* » ភិរម្យយូ ក៏ទាល់ឆ្លើយមិនរួច ហើយភិរម្យង៉ុយច្រៀងបង្អាប់ភិរម្យយូ យ៉ាងច្រើនថា *កន្លែងធ្លាប់ទៅមក ហើយជាប្រទេសរបស់ខ្លួនឯង ភិរម្យយូមិនដឹងទៅហើយ ទៅសង្ខាតសួរកន្លែងមិនដែលទៅ បើទោះជាខ្ញុំកុហក ក៏ត្រូវតែជឿខ្ញុំដែរ* ។ ភិរម្យង៉ុយបង្អាប់ទាល់តែភិរម្យយូទាល់ ចុះពីកន្លែងច្រៀង ហើយប្រជាជនអ្នកស្តាប់ទះដៃសរសើរភិរម្យង៉ុយយ៉ាងខ្លាំង ។ លោកប្រមុខខេត្តបាត់ដំបង បានប្រគល់រង្វាន់នៃជ័យជំនះដល់ភិរម្យង៉ុយ គឺសេះស ១ ក្បាល និងប្រាក់សុទ្ធ ៤០០

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



វៀលទៀត ។ ដូច្នេះហើយបានជា អ្នកចម្រៀងនានា មានការញញើតលោកណាស់ មិនសូវមាននរណាហ៊ានច្រៀងតតាំងនឹងថ្វីមាត់លោកឡើយ មានតែជំទប់ *សាន់* នៅឃុំភ្លើងឆេះរទេះ ស្រុកភ្នំពេញ ដែលជាមិត្តភក្តិ និងជាដៃគូ របស់គាត់ម្នាក់ប៉ុណ្ណោះ ទើបអាចតបតនឹងលោកបាន ។ ពេលអ្នកចម្រៀងទាំងពីរនេះ ទៅច្រៀងនៅកន្លែងណា មនុស្សម្នាប្រុសស្រី នៅភូមិស្រុកឆ្ងាយៗ បានភ្លូកទៅស្ដាប់ជាច្រើន ។

នៅពេលក្រោយមកទៀត លោក សីដេស បាននាំព្រះភិរម្យភាសាអ៊ូ ទៅជួបលោកស្រី ស៊ុយហ្សាន កាប៉ុឡែស ( Suzanne Karpeles ) ដែលជានាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ ។ នៅឆ្នាំ ១៩៣០ អ្នកស្រីនាយក សុំឱ្យអ្នកព្រះភិរម្យភាសាច្រៀងកំណាព្យរបស់គាត់ឡើងវិញទាំងអស់ បែបរង្វើលៗ ដើម្បីឱ្យអ្នកប្រាជ្ញនៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យកត់ត្រាទុក ។ ជារង្វាន់នៅពេលនោះ អ្នកស្រី *ស៊ុយសាន* បានឱ្យលោក នូវប្រាក់ ១ រៀល ជានិមិត្តរូបនៃការស្រឡាញ់វប្បធម៌អរិយធម៌ខ្មែរ ។ ដោយចង់រក្សាទុកស្នាដៃនេះឱ្យបានយូរអង្វែង សំរាប់មនុស្សជំនាន់ក្រោយ ពុទ្ធសាសនបណ្ឌិត្យ បានចាត់ចែងបោះពុម្ពស្នាដៃរបស់លោកជាប្អូនច្បាប់ ហើយក្រោយមក បានបោះបញ្ចូលគ្នាជាមួយច្បាប់វិញ ។

តាមពិត ស្នាដៃរបស់លោកមានច្រើន ប៉ុន្តែគេមិនបានកត់ត្រា ព្រោះលោកតាង៉ុយ ជាកវីដែលបង្កើតស្នាដៃដោយច្រៀងផ្ទាល់មាត់ ។

ស្នាដៃរបស់លោក ដែលយើងរកឃើញ រហូតដល់សព្វថ្ងៃ មាន ៥ គឺ ៈ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



១. ច្បាប់ល្បើកថ្មី « បទកាកគតិ » (ឆ្នាំ ១៩២២),

២. ច្បាប់កេរកាលថ្មី « បទព្រហ្មគីតិ » (ឆ្នាំ ១៩២២),

៣. សេចក្តីរំលឹកដាស់តឿន « បទពាក្យ ៧ » (ឆ្នាំ ១៩៣១),

៤. ពាក្យកាព្យប្រដៅជនប្រុសស្រី « បទពាក្យ ៧ » (មិនដឹងកាលបរិច្ឆេទ), អាចក្នុងឆ្នាំ១៩៣៥ព្រោះជាស្នាដៃទី៥ ។

៥. បណ្តាំក្រមង៉ុយ « បទព្រហ្មគីតិ » ( ក្នុងរវាងឆ្នាំ១៩៣៥ ) ។

ក្រៅពីស្នាដៃខាងលើនេះ នៅមានស្នាដៃផ្សេងទៀត ដែលគេរកមិនឃើញឯកសារសរសេរ ហើយដែលអ្នកស្រាវជ្រាវពីមុនៗ បានចាត់ទុកថាជាស្នាដៃរបស់អ្នកកវីរម្យភាសាអ៊ូ ដែរ គឺចម្រៀងស្តីអំពី ៖

- ការប្រែប្រួលនៃស្រុកទេស,
- កតញ្ញូកតវេទី,
- ត្រៃលក្ខណ៍,
- ចម្រៀងស្រី-ប្រុស ...

អ្នកកវីរម្យភាសាអ៊ូ មានភរិយាឈ្មោះ អ៊ិន ។ លោកមានបុត្រចំនួន ៦ នាក់ សុទ្ធតែប្រុស គឺ ៖

១. ឈ្មោះ ដួង

២. ឈ្មោះ ចេង

៣. ឈ្មោះ ចា

៤. ឈ្មោះ ចិន

៥. ឈ្មោះ ចុង

៦. ឈ្មោះ ចៅ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ក្នុងចំណោមកូនគាត់ទាំង ៦ នាក់ មានម្នាក់ដែលមានទេពកោសល្យខាងសំនួនវោហារ ប្រហាក់ប្រហែលគាត់នោះគឺ កូនទី ៥ ដែលគេនិយមហៅថាអាចារ្យ ចុង ។ មានពតិមានខ្លះទៀតថា គាត់នៅមានចៅម្នាក់ទៀត ដែលមានវោហារល្បីខាងច្រៀងអាយ៉ៃដែរ ហើយមានរូបរាងស្គមស្គើង ដែលគេធ្លាប់ឮឈ្មោះថា នាយស្លឹក ។ នៅពេលច្រៀងអាយ៉ៃ នាយស្លឹក តែងបង្ហាញខ្លួនគាត់ថា « *ស្រុកខ្ញុំនៅឯលិចពោធិចិនតុង កូនអាចារ្យចុងចៅអាចារ្យង៉ុយ* » ។

អ្នកព្រះភិរម្យភាសាអ៊ូ បានទទួលអនិច្ចកម្ម នៅថ្ងៃសុក្រ ៦ កើត ខែមិគសិរ ព.ស ២៤៧៩ គ.ស ១៩៣៦ ក្នុងជន្មាយុ ៧១ ឆ្នាំ ដោយជំងឺទល់លាមក ។

## សង្គមបរិយាកាសនៅកម្ពុជា
### ( ពីឆ្នាំ ១៨៦៥ ដល់ឆ្នាំ ១៩៣៦ )

នៅក្នុងរយះពេលជាង ៧០ ឆ្នាំនេះ នៅប្រទេសកម្ពុជា គេឃើញមានព្រឹត្តិការណ៍សំខាន់ៗជាច្រើន ដែលធ្វើឱ្យមានវិបរិតទូទាំងប្រទេស ទាក់ទងដល់គ្រប់វិស័យរបស់សង្គម និងប៉ះពាល់ដល់ភាពរស់នៅរបស់ប្រជាជនខ្មែរ ទូទាំងប្រទេស ។

ប្រជាជនកម្ពុជា បាត់បង់សិទ្ធិសេរីភាព និងអ្វីៗដែលខ្លួនធ្លាប់មានពីមុនៗមក ក្នុងឋានះជាម្ចាស់ប្រទេស ចាប់ពីឆ្នាំរក គ.ស ១៨៨៤ [1] គឺក្នុងពេលដែលពួកអាណានិគមបារាំង បានប្រើអំណាចរំលោភទាំងកំរោល

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



មកលើអធិបតេយ្យរបស់ប្រទេសកម្ពុជា ដោយលែងទទួលស្គាល់កម្ពុជាក្នុងលក្ខណៈជាប្រទេសស្ថិតក្នុងអាណាព្យាបាលរបស់ខ្លួន ។ ផ្ទុយទៅវិញបារាំងបានចាប់យកកម្ពុជា ធ្វើជាប្រទេសអាណានិគមរបស់ខ្លួនតែម្តង ។

ចាប់តាំងពីពេលនោះ គេឃើញមានការសើរើរៀបចំប្រទេសឡើងវិញនៅគ្រប់វិស័យ ទៅតាមប្រព័ន្ធគ្រប់គ្រងបារាំង ទាំងខាងរដ្ឋបាល ទាំងខាងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំសិក្សាធិការ ដូចជា ៖

- មានការតែងតាំងមន្ត្រីភាគច្រើនជាជនបរទេស ក្នុងអង្គការរដ្ឋបាលឱ្យត្រួតត្រាប្រទេសខ្មែរ,

- មានការវាស់វែងបែងចែកដីធ្លី និងប្រគល់កម្មសិទ្ធិឱ្យប្រជាជន ដើម្បីងាយដកហូតពន្ធដារ,

- មានការបោះពុម្ពក្រដាស់ប្រាក់ថ្មី ជំនួសប្រាក់សុទ្ធ [2],

- ប្រមូលទ្រព្យសម្បត្តិឃ្លាំងព្រះរាជទ្រព្យ យកទៅដាក់រតនាគាររួម ហៅថា Trésor unique du Royaume [3],

- ការផ្សព្វផ្សាយវប្បធម៌ និង អរិយធម៌លោកខាងលិច នៅក្នុងប្រទេស រាប់តាំងពីអក្សរ ភាសា សីលធម៌រស់នៅ សម្លៀកបំពាក់ សិល្បៈ ភ្លេង របាំ រាំ ច្រៀង ៗលៗ ។

ម្យ៉ាងទៀត នៅក្នុងឆ្នាំ ១៩១៤ - ១៩១៨ សង្គ្រាមលោកលើកទី ១ បានផ្ទុះឡើងនៅប្រទេសអឺរ៉ុប ។ ពិតមែនតែសង្គ្រាមនោះ មិនកើតឡើងលើ ទឹកដីរបស់យើង ប៉ុន្តែផលវិបាករបស់សង្គ្រាមនេះ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើប្រជាជនកម្ពុជា ។ ដោយសារប្រទេសកម្ពុជា ជាប្រទេសអាណានិគមរបស់បារាំង ដូច្នេះ ឈាមខ្មែរ ក៏កំពប់ខ្ចាយដោយសារបារាំងធ្វើ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



សង្គ្រាមនៅអឺរ៉ុបដែរ ។ ពេលនោះ បារាំងបានចាប់ប្រជាជនខ្មែរបុរសៗ ឱ្យធ្វើទាហាន ហើយមួយចំនួនធំត្រូវបានចាត់បញ្ជូនឱ្យទៅជួយច្បាំងបារាំង ។ ទាហានមួយចំនួនបានពលីនៅលើសមរភូមិ ដោយឥតមានស្គាល់ឈ្មោះ និងស្រុកកំណើតរបស់គេឡើយ [4] ។

ប្រជាជនកម្ពុជាដែលនៅក្នុងស្រុក ត្រូវទទួលរងទុក្ខវេទនា ដោយសារការហ៊ុំព័ទ្ធសេដ្ឋកិច្ចពីខាងក្រៅ ដោយសារគ្រោះធម្មជាតិ ( ទឹកជំនន់ និងរាំងស្ងួត ) បណ្ដាលឱ្យមានទុរ្ភិក្សជាទូទៅពេញប្រទេស ។ ជំងឺតម្កាត់កើតឡើង ហើយឆ្លងរាលដាលយ៉ាងរហ័ស ដោយសារខ្វះថ្នាំសង្កូវ ។ រីឯពួកអាណានិគមវិញ គិតតែជំរិតទារពន្ធដារលើមនុស្ស សត្វ និងឧបករណ៍សម្ភារៈសព្វសារពើ ដើម្បីយកទៅចំណាយក្នុងសង្គ្រាម និងដើម្បីស្ដារប្រទេសរបស់គេឡើងវិញ ក្រោយពេលសង្គ្រាមបានចប់ទៅវិញ ។ ការប្រមូលពន្ធដារលើទំនិញ និងការហ៊ុំព័ទ្ធសេដ្ឋកិច្ច និងការខកខានមិនបានផលិត បណ្ដាលមកពីគ្រោះរាំងស្ងួត នាំឱ្យមានអតិផរណាទំនិញសព្វសារពើចេះតែឡើងថ្លៃរៀងរាល់ថ្ងៃ ។ ទន្ទឹមនឹងព្រឹត្តិការណ៍ខាងលើនេះ ពួកឈ្មួញបរទេស និងអ្នកប្រកបមុខរបរលក់ដូរ ឆ្លៀតឱកាសកេងប្រវញ្ច គៃបន្លំយកចំណេញ ដើម្បីធ្វើមានបានពីលើខ្នងប្រជាជនខ្មែរ ដែលភាគច្រើនជាកសិករមិនសូវបានរៀនសូត្រ ទាំងខាងអក្សរសាស្ត្រ ទាំងខាងលេខនព្វន្ត ។

---

[1] នៅក្នុងសៀវភៅឈ្មោះ « រាជាធិបតេយ្យកម្ពុជា និងព្រះរាជបូជនីយ-កិច្ចដើម្បីឯករាជ្យ (La Monarchie Cambodgiènne et la

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



Croisade Royale pour l'Indépendance) » សម្ដេចព្រះនរោត្តមសីហនុ បានរៀបរាប់យ៉ាងពិស្ដារ អំពីខ្លឹមសារអនុសញ្ញា ឆ្នាំ ១៨៨៤ ( ទំព័រ ៩៣ និងបន្តបន្ទាប់ ) ។

- ឯកសារមហាបុរសខ្មែរ របស់លោក អេង សុត, ត្រង់រជ្ជកាលព្រះនរោត្តម ភាគខាងចុង ។

[2] នៅមុនសតវត្សទី ១៥ ការផ្លាស់ប្ដូរទំនិញសំខាន់ៗ ក្នុងការលក់ដូរក្នុងស្រុក និងក្រៅប្រទេស គេធ្វើឱ្យមានការផ្លាស់ប្ដូរទៅវិញទៅមក ដោយយកទំនិញប្ដូរនឹងទំនិញ យកមាសទៅប្ដូរក៏មាន ( សៀវភៅ Le Cambodge បោះពុម្ពផ្សាយដោយក្រសួងឃោសនាការ នៃរាជរដ្ឋាភិបាលកម្ពុជា ភ្នំពេញ, ឆ្នាំ ១៩៦២ ),

- កំណត់ហេតុ ស្ដីអំពីទំនៀមទម្លាប់របស់ប្រទេសកម្ពុជា, របស់ ចូវតាក្វាន់ (Mémoires sur les coutumes du Cambodge de Tcheou Takouan; Œuvres postumes de Paul Pelliot Adrien - Maison- neuvre Paris 1951),

- សិលាចារឹកស្ដុកកក់ធំ,

- ឯកសារមហាបុរស,

លុះមកដល់ឆ្នាំ ១៥៩៥ ក្នុងរជ្ជកាលព្រះសត្ថាទីមួយ គេបានរកឃើញមានប្រាក់ដែលបោះចាយលើកដំបូង ។ រហូតមកដល់រជ្ជកាលព្រះអង្គឌួង ទើបមានការបោះប្រាក់ចាយសាជាថ្មី ក្នុងរវាងឆ្នាំ ១៨៤៧ ត្រង់រជ្ជកាលព្រះអង្គឌួង) ។

- សៀវភៅ La Monarchie Cambodgiènne និងសៀវភៅ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



Le Cambodge ដូចបញ្ជាក់ខាងលើ ។

[3] បារាំងបានប្រមូលសម្បត្តិព្រះរាជទ្រព្យ យកទៅដាក់រតនាគាររូម នៅក្នុងឆ្នាំ ១៨៩១ ( សូមអានឯកសារមហាបុរសខ្មែរ ) ។

[4] កាលពីមុនឆ្នាំ១៩៧៥ គេឃើញមានរូបសំណាកធ្វើអំពីស្ពាន់យ៉ាងធំ តម្កល់កណ្តាលសួន នៅខាងកើតស្ថានទូតបារាំង ត្រង់មុំវត្តចិនដំដែក ដែលគេនិយមហៅថា រូបពីរ ។ រូបសំណាកនោះ បារាំងបានកសាងដើម្បីឧទ្ទិសចំពោះទាហានបារាំង និងខ្មែរ ដែលបានពលីជីវិតក្នុងការជួយច្បាំងបារាំង ។ ក្រោយឆ្នាំ ១៩៧៥ ក្នុងពេលដែលខ្មែរក្រហមឡើងកាន់អំណាច រូបសំណាកនេះ ត្រូវបានគេកំទេចចោលទាំងស្រុង ។

ប្រមូលចងក្រងពតិមានដោយ

យី ធន់

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel